# ការសម្ភាសរបស់អ៊ីបន សេងឡូន

កះ អ្នកធ្វើការសំភាសន៍ ហេង សុជីវី ខះ អ្នកត្រូវគេសំភាសន៍ បន សេងឡូន

កះ ជាដំបូងសូមជំរាបសួរអ៊ី!!

ខះ ចាស!

កះ
ចាស!ថ្ងៃនេះខ្ញុំមានឧកាសដើម្បីមកធ្វើការសំភាសន៍អ៊ីផ្ទាល់ដែលរូបខ្ញុំនឹងបានធ្វើការងារមួយស្មាគចិត្តពីខាងគំរោងរបស់ខាងសាលាBYU
នៅខាងសហរដ្ឋអាមេរិកណាអ៊ីដែលគេតំរូវអោយធ្វើការសំភាសន៍ដល់ប្រជាជនកម្ពុជាដែលសលគាត់មានវ័យចាប់ពី៣៥ឆ្នាំឡើង
ចាសអំពីជីវៈប្រវត្តិរបស់គាត់ខ្សែជីវៈរបស់គាត់តាំងពីតូចមកដល់បច្ចុប្បន្ននឹងបទពិសោធន៍ជីវិតរបស់គាត់តាំងពីតូចនឹងមករហូតដល់វ័យបានប៉ុណ្ណឹងអ៊ីមានបានឆ្លងកាត់នូវជីវិតបែបណាខ្លះ?
ហើយចឹងថ្ងៃនេះនឹងខ្ញុំមានឧកាសដើម្បីនឹងធ្វើការសំភាសន៍ដ៏អ៊ីផ្ទាល់ចឹងតើអ៊ីនឹងអនុញ្ញាតដើម្បីអោយខ្ញុំធ្វើការសំភាសន៍ដល់អ៊ីដែរឬទេ?ហើយមានការសំភាសន៍អ៊ីនឹងថតសំលេងរបស់អ៊ីហើយនឹងបានសំភាសន៍អ៊ីសំរាប់ថ្ងៃនឹងដែរឬទេ?

ខះ អត់អ៊ីទេអូនអាចធ្វើការសំភាសន៍បាន។

កះ ចាស!ចឹងជាដំបូងអ៊ីមានឈ្មោះអ្វីដែរ?

ខះ ខ្ញុំមានឈ្មោះថា បន សេងឡូន។

កះ ចាស!អ៊ីហើយអ៊ីហើយសព្វថ្ងៃនឹងឈ្មោះរបស់សព្វថ្ងៃមានឈ្មោះអ្វីដែរ?

ខះ មានឈ្មោះថាបន សេងឡូននឹងតែម្តង។

កះ ចឹងឈ្មោះរបស់អ៊ីមួយនឹងត្រូវជាមួយនឹងអត្តសញ្ញាប័ណ្ណដែរឬទេ?

ខ៖ ចាស!ត្រូវជាមួយនឹងអត្តសញ្ញាប័ណ្ណ។

ក៖ ហើយអ៊ីមានឈ្មោះហៅក្រៅដែរឬទេ?

ខ៖ អត់មានទេ។

ក៖ ហើយឈ្មោះនឹងតើនរណាគេជាអ្នកដែលបានដាក់ឈ្មោះនឹងអោយ?

ខ៖
កាលនឹងឈ្មោះនឹងម្ដាយឪពុករបស់ខ្ញុំនឹងគាត់ជាអ្នកដែលបានដាក់ឈ្មោះអោយឪពុករបស់ខ្ញុំនឹងគាត់បានដាក់ឈ្មោះអោយ។

ក៖ ចាស!ហើយវាមានអត្តន័យយ៉ាងម៉េចដែរទៅ?

ខ៖
ចាស!អត់ដឹងថាវាមានអត្តន័យម៉េចដែរក៏ប៉ុន្តែគ្រាន់តែគាត់បានប្រាប់យើងថាដោយសារតែគាត់បានស្រលាញ់ឈ្មោះនឹងចឹងហើយគាត់ក៏បានដាក់អោយឈ្មោះនឹងតែម្ដងទៅនឹងចាស។

ក៖ហើយអ៊ីសព្វថ្ងៃនឹងមានអាយុបានប៉ុន្មានហើយ?

ខ៖ ខ្ញុំសព្វថ្ងៃនឹងមានអាយុប្រមាណបានជា៥៦ នឹងហើយមានអាយុ៥៦ឆ្នាំហើយចាស។

ក៖ ចាស!ចឹងអ៊ីបានកើតនៅក្នុងឆ្នាំណាដែរ?

ខ៖ ខ្ញុំបានកើតនៅក្នុងឆ្នាំ១៩៦២ ។

ក៖ ចុះថ្ងៃខែឆ្នាំកំណើតរបស់អ៊ីអ៊ីមានបាននៅចាំដែរឬទេ?

ខ៖ ខ្ញុំកើតនៅក្នុងថ្ងៃទី៤ខែ៩ឆ្នាំ១៩៦២។

ក៖
ចាស!ហើយចុះចំពោះឆ្នាំខ្មែររបស់យើងនឹងដូចជាឆ្នាំជូតឬក៏ឆ្នាំឆ្លូវអីជាដើមចឹងមួយណាដែរ?

ខ៖ ខ្ញុំបានកើតនៅក្នុងឆ្នាំថោះ។

ក៖ ចាស!ចឹងអ៊ីបានកើតនៅក្នុងឆ្នាំថោះហើយចឹងអ៊ីសព្វថ្ងៃនឹងអ៊ីមានទីលំនៅនៅឯណាដែរ?

ខ៖ ខ្ញុំមានទីលំនៅសព្វថ្ងៃនឹងមានទីលំនៅនៅស្រុកសន្សំកុសលអីនៅខាងវត្តសន្សំកុសល។

ក៖ អីអ៊ីអាចធ្វើការបញ្ជាក់បានដែរឬទេថាអ៊ីមានទីលំនៅនៅក្នុងភូមិសង្កាត់ណាដែរ?

ខ៖ នៅក្នុងសន្សំកុសល ភូមិប៉ុន្មានខ្ញុំវាបានភ្លេចបាត់ទៅហើយណា?

គ៖ នៅក្នុងភូមិសន្សំកុសល៣។

ខ៖ ចាស!ចឹងនៅក្នុងភូមិសន្សំកុសល សង្កាត់បឹងទំពុន ខណ្ឌស្ទឹងមានជ័យចាស។

ក៖ ចាស!ហើយស្រុកកំណើតអ៊ីនៅឯណាដែលអ៊ី?

ខ៖ ស្រុកកំណើតនឹងនៅឯកោះធំ។ នៅក្នុងភូមិកោះធំ ស្រុកកោះធំនៅក្នុងខេត្តកណ្តាល។

ក៖ ចាស!ហើយអីអ៊ីសព្វថ្ងៃនឹងមានមុខរបរជាអ្វីដែរ?

ខ៖ ខ្ញុំសព្វថ្ងៃនឹងមានមុខរបរជាអីធ្វើការងារជាអ្នកជួយលក់បាយអោយបងប្អូន។

ក៖ ចឹងសព្វថ្ងៃនឹងអ៊ីមានមុខរបរតែមួយទេ?

ខ៖ ចាស

ក៖ ហើយអ៊ីធ្វើការងារពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែរ?

ខ៖ ធ្វើការងារនឹងត្រូវតែងើបពីដេកម៉ោង៥ព្រឹក។

ក៖ អូ!ម៉ោង៥ព្រឹកចាប់ផ្តើមធ្វើ។

ខ៖
នឹងហើយម៉ោង៥ឡើងពេលព្រឹកភ្លឺនឹងចាប់ផ្តើមភ្ញាក់ហើយមកដាក់ដាំបាយចឹងទៅព្រោះអីយើងលក់បាយសំរាប់ពេលព្រឹក
សំរាប់បាយថ្ងៃត្រង់ហើយទំរាំតែបានរួចបាយហើយម៉ោងបាន៣ល្ងាចនឹងបានរួចដៃចាស។

ក៖ អូ!ចឹង?

ខ៖ ចាស!!

កៈ ហើយការងារនឹងអ៊ីអាចរកប្រាក់ចំណូលបានប៉ុន្មាននៅក្នុង១ខែ?

ខៈ នៅក្នុង១ខែចឹងទៅខ្ញុំអាចរកប្រាក់ចំណូលបានជាង១០០ដុល្លា។

កៈ ប្រាក់នឹងគឺថេរចឹងតែម្តង?

ខៈ នឹងហើយព្រោះអីយើងត្រូវស៊ីប្រាក់ខែគេចឹងណាចឹងទៅយើងបានតែប៉ុណ្ណឹងទេចាស។

កៈ ចឹងអីសំរាប់ការស្នាក់នៅអីវិញពេលដែលពេលល្ងាចឡើងនឹងអ៊ីត្រូវជិះទៅផ្ទះវិញចឹងទៅ?

ខៈ
អត់បានទៅផ្ទះរបស់ខ្លួនវិញផងខ្ញុំពេលដែលធ្វើការងារហើយទៅក៏នៅជាមួយនឹងផ្ទះប្អូននឹងទៅ។

កៈ នៅនឹងទៅចាស

ខៈ ចាស!នៅជាមួយនឹងផ្ទះប្អូននឹងរហូតមក។

កៈ ចាសៗហើយអ៊ីសំរាប់កាលពីដើមមកនឹងអ៊ីបានរៀនដល់កំរិតណាដែរ?

ខៈ
តាំងពីឆ្នាំ១៩៧៥ឆ្នាំនឹងខ្ញុំបានរៀនត្រឹមបានថ្នាក់ទី៩កាលនឹងចូលជាទី៩ចឹងហើយពេលនឹងទៅ៨ហើយត្រូវចូលរៀនទៅ៩កាលនឹងនៅក្នុងសម័យចាស។

កៈ ចាសៗ

ខៈ ចាស!!!

កៈ ចឹងកាលនឹងអ៊ីបានសិក្សានៅសាលានៅឯណាដែរ?

ខៈ កាលនឹងខ្ញុំបានសិក្សានៅខាងសាលានៅបឹងត្របែកខាងត្បូង
នេះនៅខាងសាលាបឹងត្របែកខាងត្បូងយើងនឹង ដែងនៅជិតខាងអាគារដំបូងខ្ពស់យើងនេះ។

កៈ ចាស!!

ខៈ ចាស!!

កៈ ចាស!ចឹងអ៊ីអាចធ្វើការសរសេរ អាន អាចនឹងធ្វើការគិតលេខអីបាន?

ខៈ ចាស!បានបានធម្មតាទេ។

កៈ ហើយអ៊ីបានចេះប៉ុន្មានភាសាដែរ?

ខៈ ហឺ!ខ្ញុំបានចេះតែខ្មែរទេហើយបើថាភាសាបារាំងអីនឹងខ្ញុំចេះតែបន្តិចៗនោះទេ ខ្ញុំវាបានភ្លេចទៅអស់ហើយកាលនឹងនោះ។

កៈ ចាស!

ខៈ
នឹងហើយកាលនៅសម័យជំនាន់របស់ខ្ញុំនឹងកាលនឹងវាគេអោយតែរៀនបារាំងទេណាគេមិនទាន់អោយមានរៀនបារាំងនោះទេ
ហើយកាលនឹងភាសាខ្មែរយើងអីនឹងយើងនៅចេះសរសេរបានចេះអានបានដូចថាយើងអាចនឹងអានបានហើយភាសាបារាំងនឹងចេះបានមើលអីតិចតួច។

កៈ ចឹងអ៊ីចឹងភាសាខ្មែរអាចអានហើយភាសាបារាំងនឹងអ៊ីអាចនឹងចេះតិចតួចចឹងមានទេអ៊ី?

ខៈ ចាសកាលនឹងវាចេះបានតែបន្តិចបន្តួចចឹងនោះ
កាលនឹងខ្ញុំមកដល់ឥឡូវនឹងចេះបានត្រឹមមើលអក្សរ អា បេ សេអីនឹងអាចអាន អា បេ សេអីនឹងអាចអានបានចប់តែបើថាអោយយើងប្រកបទៅអីផ្សេងនឹងវាមិនចេះទេព្រោះអីវាបានរៀនឹងយូរដែលហើយចឹងវាភ្លេចខ្លះទៅអស់ហើយដែលនឹង។

កៈ ចាស!

ខៈ ចាស!

កៈ រៀនជាមួយនឹងគ្រូជាជនជាតិបារាំងផ្ទាល់កាលនឹង?

ខៈ រៀនជាមួយនឹងគ្រូខ្មែរ
កាលនៅជំនាន់នឹងនោះគ្រូនឹងគាត់គឺជាជនជាតិខ្មែរយើងទេដូចជាពេលនឹងយើងបានរៀននឹង

វាមានម៉ោងបារាំងទៅម៉ោងខ្មែរយើងចឹងទៅ
បានថាកាលនឹងវាពេលខ្លះម៉ោងខ្មែរយើងចឹងយើងរៀនម៉ោងខ្មែរយើងចឹងទៅណា។

ក៖ ចាស អូល្អមែនទែន ហើយចឹងមូលហេតុអ្វីដែរ ដែលពេលនឹងអ៊ីបានឈប់រៀន?

ខ៖
ព្រោះអីកាលនឹងវាបានបែកចូលទៅក្នុងសម័យជំនាន់អាពតចឹងទៅនៅក្នុងជំនាន់ឆ្នាំ១៩៧៥
ហើយក៏បានចូលក្នុងសម័យជំនាន់ពពតនឹងចឹងទៅក៏អត់បានរៀន។

ក៖ ចាស!

ខ៖ នឹងហើយ

ក៖ ចាស!ហើយឪពុកម្ដាយអ៊ីមានឈ្មោះអ្វីដែរ?

ខ៖ ចាស!ម្ដាយរបស់ខ្ញុំនឹងគាត់មានឈ្មោះថាអីឈ្មោះអី ហាក់ បន
ម្ដាយរបស់ខ្ញុំនឹងគាត់មានឈ្មោះថា មួយ ញ៉ឹក។

ក៖ ចាស!ហើយពួកគាត់មានទីលំនៅនៅឯណាដែរ?

ខ៖ ពួកគាត់មានទៅលំនៅនៅក្នុងភូមិកោះធំ ស្រុកកោះធំនឹងចឹងតែម្ដង
កាលនឹងគាត់មានទីលំនៅនៅក្នុងស្រុកកោះធំ
ខេត្តកណ្ដាលយើងនឹងតែម្ដងហើយគាត់បានរស់នៅទីនោះរហូតមកដល់បច្ចុប្បន្ននឹងហើយចំ
ណែកឯប៉ារបស់ខ្ញុំនឹងគាត់បានស្លាប់នៅក្នុងជំនាន់អាពត។

ក៖ ហើយអ៊ីសព្វថ្ងៃនឹងមានទីលំនៅនៅឯណាដែរ?

ខ៖ ខ្ញុំសព្វថ្ងៃនឹងមានទីលំនៅនៅនឹងឯង។

ក៖ ចាស!ហើយអ៊ីមានបងនិងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានបងនឹងប្អូននឹងតែខ្ញុំម្នាក់ឯងទេ។

ក៖ ចាស!ចឹងអ៊ីជាកូនទោលនៅក្នុងគ្រួសារចាស។

ខ៖
ព្រោះអីកាលនឹងបងនឹងប្អូនរបស់ខ្ញុំនឹងគាត់បានស្លាប់អស់ហើយពួកគាត់បានស្លាប់នៅក្នុងជំនាន់អាពតអស់ហើយ។

ក៖ ហើយចឹងកាលនឹងអីម៉េចបានជាពួកគាត់បានស្លាប់អស់ចឹង?

ខ៖
កាលនឹងខ្ញុំដឹងទោះបីជាកាលនៅក្នុងជំនាន់សម័យពពតនឹងយើងត្រឹមតែមានអាយុតែ១២ឆ្នាំក៏ដោយ គ្រាន់តែបានបែកចូលជំនាន់អាពតនឹងយើងនឹងយើងបានអាយុ១២ឆ្នាំហើយ។

ក៖ ចាស!

ខ៖ ហើយចឹងយើងក៏បានដឹងថាគាត់បានស្លាប់អស់ហើយ។

ក៖ កាលនឹងគេបានប្រាប់អី?

ខ៖
គេមិនបានប្រាប់ទេកាលនឹងយើងនឹងបានឃើញតែម្ដងខ្ញុំបានមើលឃើញគាត់នឹងផ្ទាល់ភ្នែករបស់យើងនឹងតែម្ដងថាគាត់នឹងបានអត់បាយកាលនឹងមានប៉ារបស់ខ្ញុំនឹងគាត់បានស្លាប់ដោយសារតែអត់មានបាយសំរាប់ហូបហើយប្អូនរបស់ខ្ញុំនឹងក៏គាត់បានស្លាប់ដោយសារតែគាត់អត់មានបាយសំរាប់ហូតដែលស្លាប់អត់បានទាំងអស់នឹង។

ក៖ ហឺ!

ខ៖
ហើយពេលនឹងកាលនឹងពេលដែលស្លាប់នឹងគេបានសែងគាត់ទៅនឹងនៅនឹងមុខយើងតែម្ដងនឹងតែម៉ងហាហ៎ នឹងហើយហើយកាលនឹងគេបានសែងគាត់ទៅនឹងយើងក៏បាននៅនឹងដែរ។

ក៖ ចឹងមានន័យថាពេលដែលគាត់ស្លាប់នឹងគឺដោយសារតែជំងឺចឹង?

ខ៖ នឹងហើយតែគាត់ស្លាប់នឹងដោយសារតែមានជំងឺបណ្ដាលមកពីជំងឺអត់មានបាយដឹងទេគេថាវាមិនមែននឹងជំងឺផងគេថាដោយសារតែគាត់វាហេវពេកបានជាមានជំងឺហេវដោយសារអត់មានបាយហើយទៅក៏ស្លាប់។

កៈ ចុះចំណែកឯម្ដាយរបស់អ៊ីវិញ?

ខៈ
កាលនៅជំនាន់បែកអាពតមកនឹងម្ដាយរបស់ខ្ញុំនឹងគាត់បានបែកពីអាពតមកនៅក្នុងឆ្នាំ១៩៧៥ ពេលបែកបានចូលទៅក្នុងសម័យនោះនឹងហើយគាត់បានស្លាប់កាលនឹងមិនថាគាត់កើតអីនោះទេគឺថាគាត់បានឈឺស្លាប់តែម្ដងនឹង
គាត់ស្លាប់នឹងកាលនឹងគាត់មានអាយុប្រហែល៣៣ឆ្នាំកាលនៅជំនាន់នឹងនោះ។

កៈ ហើយគាត់បានឈឺអ្វីគេដែលអ៊ី?

ខៈ
គាត់មិនបានដឹងថាគាត់នឹងបានឈឺអីផងនឹងគាត់ដឹងតែពេលនឹងគាត់បានមានជំងឺម្យាងគឺជំងឺខ្យល់គ។

កៈ អូ

ខៈ
កាលនឹងវាមិនបានដឹងថាកាលនឹងគាត់មានជំងឺអ្វីនោះទេគ្រាន់តែបានដឹងថាពេលនឹងគាត់មានជំងឺម៉្យានឹងគឺគេហៅថាជាជំងឺខ្យល់គហើយពេលនឹងគាត់មានជំងឺនឹងមានកូនបាន៥នាក់ដែរ កាលនឹងនោះហើយកាលនឹងខ្ញុំនឹងជាកូនទី២គេ។

កៈ ចុះអ៊ីកាលនឹងអ៊ីមានបានចាំឈ្មោះរបស់បងនឹងប្អូនរបស់អ៊ីទាំងអស់គ្នាដែរឬទេ?

ខៈ នឹងហើយកាលនឹងប្អូននឹងបងរបស់ខ្ញុំនឹងគាត់មានឈ្មោះអើយ បនសន់
ហើយខ្ញុំនឹងមានឈ្មោះថាបន សេងឡុន ប្អូនរបស់ខ្ញុំទី៣នឹងវាមានឈ្មោះថា បន ស៊ីណា
ហើយប្អូនរបស់ខ្ញុំទី៤នឹងគេមានឈ្មោះថាបន ដារ៉ា
ហើយប្អូនរបស់ខ្ញុំទី៥នឹងគេមានឈ្មោះថាបន ចំរើនហើយប្អូនទី៦គេមានឈ្មោះថាបនចំ រុងស្រី
ទាំងអស់នឹងគេបានស្លាប់នៅក្នុងជំនាន់អាពតអស់ទៅហើយទាំងអស់៥នាក់នឹងមាននៅសល់តែខ្ញុំមួយនាក់នឹងឯង។

កៈ ចឹងកាលនឹងគាត់មានស្រីប៉ុន្មាននាក់ហើយប្រុសមានប៉ុន្មាននាក់ដែរ?

ខ៖ កាលនឹងបានបងនឹងប្អូន៦នាក់នឹងស្រី៣ប្រុស៣នាក់។

ក៖ ចឹងកាលនឹងតើគាត់មានក្រុមគ្រួសារដែលឬទេ?

ខ៖ កាលនឹងបានស្លាប់នៅក្នុងជំនាន់អាពតទាំងអស់នឹង។

ក៖ ឬក៏កាលនឹងគាត់នៅលីវទេ?

ខ៖ កាលនឹង ពួកគាត់ទាំងអស់គ្នានឹងនៅតូចៗទេកាលនឹងនោះ

គ៖ កាលនឹងពួកគេនឹងនៅតូចៗទាំងអស់គ្នានឹង

ក៖ អូ!សោកស្ដាយណាស់កាលនឹង

គ៖ ចាស៧ទៅ៨នាក់នឹងស្លាប់ទាំងអស់ចាស

ខ៖
ចាស!កាលនឹងបងនឹងប្អូននឹងវានៅតូចៗទាំងអស់មានតែប្អូននឹងគេខ្លះនឹងនៅមានអាយុត្រឹមតែ២ខួបអីចឹងទៅហើយពេលនឹងគេបានត្រឹមតែអាយុ២ខួបអីចឹងទៅក៏បានស្លាប់ចឹងទៅ។

ក៖
កាលនឹងពួកគាត់ទាំងអស់គ្នានឹងតើពួកគាត់នឹងគេបានយកគាត់ទៅសំលាប់នឹងទាំងអស់គ្នាតែម្ដង?

ខ៖
ចាស!ចឹងកាលនឹងខ្ញុំបាននៅនឹងកន្លែងនឹងដែលនឹងពេលនឹងកាលដែលគេបានជំលៀសនឹងនោះកាលនឹងគេបានធ្វើការជំលៀសនឹងនៅឯខេត្តពោធិសាត់។

ក៖ ចឹងកាលនឹងគេបានជំលៀសទៅទាំងក្រុមគ្រួសាររបស់អ៊ុំទាំងអស់គ្នាតែម្ដង?

ខ៖
កាលនឹងគេបានជំលៀសទៅនឹងទាំងក្រុមគ្រួសារតែបានរស់នឹងបានតែ២នាក់ទេកាលនឹងព្រោះអីកាលនឹងគេបានប្រើខ្លាំងពេកហើយស្លាប់នឹងស្លាប់ដោយសារតែអត់បាយតែម្ដងនឹង។

ក៖ ចុះកាលនឹងគេបានប្រើអ៊ុំអោយធ្វើអ្វីគេខ្លះ?

ខ៖
កាលនឹងគេបានប្រើអ៊ុំនឹងកាលនឹងអ៊ុំបាននៅជាក្រុមកុមារនៅនឹងកងកុមារហើយទៅកាលនឹងវាមានសភាពកាលនឹងវាមិនស្ងួវជាស្រួលចឹងហើយកាលនឹងយើងនឹងក៏បានចេញទៅពីកងកុមារនឹងទៅចូលក្នុងកងថ្មីនៅកណ្ដាលមួយទៀតដែលគេបានហៅថាជាកងយុវននឹងកាលនឹងនោះ។

ក៖ ចាស!

ខ៖
ចាស!នឹងហើយកាលនឹងពេលដែលទៅនៅនឹងវាមិនកើតចឹងទៅអ៊ុំនឹងក៏បានទៅនៅជាមួយនឹងកងយុវនវិញចឹងកាលនឹងនោះព្រោះអីកាលនឹងនៅក្នុងកងយុវននឹងគេមានកងកុមារប្រហែលជា៣ទៅ៤កងឯនោះកាលនឹង កាលនឹងគេមានកងកុមារ កងយុវន កងចល័ត
នឹងកងចល័តពិសេសឯនោះកាលនឹងនោះមួយនៅកងចល័តពិសេសហើយមួយទៀតនឹងនៅក្នុងកងចល័ត ហើយខ្ញុំនឹងបាននៅក្នុងយុវន
ចឹងកាលនឹងនោះកងមួយនឹងវានៅលើកងកុមារបន្តិចព្រោះអីកាលនឹងយើងនឹងវាបាននឹកឃើញបានថាបើសិនជាយើងនឹងចឹងយើងនឹងហូបមិនឆ្អែកនោះទេតែបើថាយើងបាននៅក្នុងកងកុមារចឹងយើងនឹងវាបានតែបាយនឹងវាបានតិចហើយបបរនឹងវាបានតែបន្តិចនោះទេ។

គ៖កាលនឹងវាមិនឆ្អែកដូចតែគ្នានឹងគ្រាន់តែថាពេលនឹងវារាងគ្រាន់បើជានៅក្នុងកងកុមារ

ខ៖ នឹងហើយវាបានគ្រាន់បើជាង

គ៖ ហើយកាលនឹងវាបានពេញវ៉ៃយចឹងគេបានបែកដូចតែគ្នានឹង

ខ៖
ហើយកាលនឹងខ្ញុំវាបាននៅក្នុងអាយុ១២ទៅ១៣ឆ្នាំនឹងចឹងហើយកាលនឹងយើងនឹងវានៅរាងតូចចឹងណា
វានៅតូចចឹងហើយពេលដែលយើងបានដើរនៅជាមួយនឹងគេជាអ្នកធំៗចឹងទៅយើងនៅតាមសង្ឃឹមខ្លះហើយនិយាយទៅនឹងវានឹងវាមិនមានអីទេកាលនឹងនោះប៉ុន្តែគ្រាន់តែយើងនឹងវាបានហូបបានខ្លះចឹងទៅ វាគ្រាន់បើជាងយើងនៅនឹងកន្លែងដែលថាយើងបានហូបតិចបំផុត។

គ៖ ដូចថាវាបានតិចតួចណាស់គេអោយនឹងនោះ

ខ៖ ហ៊ឺៗនិយាយទៅនឹងវាអត់តែម្តងនឹងវាអត់តែម្តង។

ក៖
ចាស!ហើយពេលនឹងនោះបាយគេបានអោយយើងដែលព្រោះអីពេលនឹងមានគេភាគច្រើននឹងគេបានអោយដែលប៉ុន្មានគេបានអោយជាបបរ។

ខ៖
ខ្ញុំនឹងកាលនៅក្នុងខេត្តងស្រុកពោធិសាត់នឹងកាលដែលអត់មែនទែននឹងអង្ក១កំប៉ុននឹងគ្នាចំនួន៥០នាក់ខាងខ្ញុំនឹងនោះ
ហើយបបរនឹងវាបានតែ១ស្លាបព្រាបាយយើងទេកាលនឹងនោះហើយកាលនឹងបបរ១ចាននឹងបានអង្កប្រហែលជាបាន១ស្លាបព្រាបាយហើយគ្រៅពីនឹងមានដែលប៉ុន្តែមានសុទ្ធតែទឹកឡើងមួយផ្តិលតែម្តងហើយបើអំបិលវិញនឹងគេបានចែកអោយប៉ុន្តែបានប្រហែលជា១០គ្រាប់។

ក៖ ចឹងកាលនឹងគេមានចែកជាអំបិលអោយដែរ?

ខ៖
នឹងហើយកាលនឹងគេមានចែកជាអំបិលដែលប្រហែលជា១០គ្រាប់កាលនឹងព្រោះអីកាលនឹងសំរាប់ដែលយើងនឹងអត់មានម្ហូបកាលនឹងពេលដែលដាច់ម្ហូបនឹងគេបានអោយយើងនឹងបានអំបិល១០គ្រាប់។

ក៖ អឺស!

ខ៖ នឹងហើយបានតែអំបិល១០គ្រាប់នឹងហើយ

ក៖ ហើយកាលនឹងអ៊ីគេមានបានអោយពិសារបានប៉ុន្មានពេលដែរ?

ខ៖ ក្នុង១ថ្ងៃចឹងគេបានអោយ២ពេល។

ក៖ បាន២ពេល ពេលល្ងាចនឹងពេលថ្ងៃ?

ខ៖ ចាស!ពេលល្ងាចនឹងសំរាប់ពេលថ្ងៃត្រង់។

កៈ អូចឹងវាពិបាកណាស់

ខៈ នឹងហើយ

គៈ ក្មេងជំនាន់ក្រោយនឹងវានៅមិនទាន់ជាស្គាល់នោះទេ។

ខៈ នឹងហើយក្មេងសម័យជំនាន់ក្រោយនឹងនូវមិនទាន់បានស្គាល់នោះទេ ក្មេងជំនាន់ក្រោយនឹងវានៅមិនទាន់ស្គាល់អីនោះទេ។

គៈ
នឹងហើយកាលនឹងវាមិនទាន់ជាបានស្គាល់ថានៅជំនាន់នោះមានរស់ជាតិយ៉ាងម៉េចនោះទេ បើកាលសម័យស្រុករអោយុដែលមានវ័យស្របារគ្នានឹងបានជាគេដឹងថាវាមិនន័យនឹងបានជួប ការលំបាកអីគេខ្លះព្រោះអីគេបានឆ្លងកាត់រួចទៅហើយ។

ខៈ នឹងហើយកាលនឹងមានតែចឹងឯងមានតែអ្នកដែលកើតទាន់ទេបានដឹង។

កៈ ចាស!

ខៈ
ហើយកាលនឹងអាពតនឹងវាមានផែនការអាក្រក់ទៀតដល់តែបានពេលចូលឆ្នាំអីចឹងទៅវាបាន ដាក់អាហារនឹងមានម្ហូបជាច្រើនសំរាប់អោយវាបានហូបសំរាប់ពេលចូលឆ្នាំ៣ឆ្នាំចំនួន៣ថ្ងៃនឹង ហើយពេលដែលបានហូបហើយនឹងវាមានអី ពេលនឹងវាឡើងធ្លាយក្រពះស្លាប់ទៅ

គៈ កាលនឹងវាអោយហូប១ឆ្អែកហើយមានអីហូបឡើង១ឆ្អែកនឹងឡើងឆ្អល់

ខៈ
វាអោយយើងហូបនឹងបាន៣ថ្ងៃណាហើយគ្រាន់តែអ្នកដែលបានហូបហើយនឹងវាមានអីស្លាប់ ដូចនេះចឹង

កៈ ហឺ!

ខៈ ព្រោះអីក្រពះរបស់យើងនឹងវាឡើងទៅជារូមតូចហើយនឹង

គៈ ក្រពះយើងឡើងតូចហើយឡើងប៉ុន្មានខែប៉ុន្មានឆ្នាំហើយ

ក៖ ចាស!

ខ៖ នឹងហើយឡើងក្រពះរបស់យើងនឹងឡើងអត់បានបាយហូបឡើងរាប់ឆ្នាំហើយនឹង តែក្រោយមកនឹងវាចាប់ផ្តើមដាក់ផែនការចឹងមកអោយហូបមួយឆ្អែក៣ថ្ងៃចូលឆ្នាំនឹងដែលវាពួយអោយយើងបាយ៣វែក ដែលប៉ិនៗកដៃអីចឹងដែលគេបានចែកមកសំរាប់បបរនឹងណាហើយមានបង្អែម សំរាប់អោយយើងហូបហើយមាន បង្អែមស្ករឡើង១ពៀងសំរាប់អោយយើងទៅដូសហូបទៅចឹងទៅ ហើយគេមានខដែលដាក់លាយជាមួយនឹងសាច់ជ្រូកហើយគេបានយកទៅឆាចឹងទៅហើយសំម្លនឹងឡើងសុទ្ធតែសាច់ហើយរយៈពេល៣នឹងគេបានហៅយើងអោយទៅប្រជុំដែលវាមានចំនួន៣ថ្ងៃនឹងគេបានហៅយើងអោយទៅប្រជុំទាំង៣ថ្ងៃនឹងតែម្តងហើយរួចការប្រជុំហើយនឹងបានជាគេហៅយើងអោយទៅញុំាបាយដែលចំនួន៣ថ្ងៃនឹងវាបានអោយយើងនឹងបានញុំាឆ្អែកមានខ្លះទៅគេមានឆុងទឹកដោះគោអោយយើងហូបទៅហើយបើយើងចង់ធ្វើអីចឹងក៏គេអោយយើងហូបចឹងទៅតែគ្រាន់តែពេលនឹងវាមិនទៅបានខាប់នឹងគេនោះទេកាលនឹងទឹកដោះគោនឹងវារាងរាវៗ

គ៖ ហើយយើងវាមិនដែលស្គាល់ទឹកដោះគោដែលទេហោស?

ខ៖ ហាហា!

ក៖ ហា!

គ៖ ចឹងទៅ!

ខ៖ អត់ទេពេលនឹងវាបានហូបទឹកដោះគោចឹងណា ហើយកាលនឹងទឹកដោះគោនឹងវាដូចជាទឹកវានឹងវារាងនៅរាងថ្លាៗម៉េចគេទេដូចជាអីចឹងវាមិនបានមើលទៅឃើញថាវាខាប់ដូចជាទឹកដោះគោយើងឥឡូវចឹង។

ក៖ ចាស!

ខ៖ នឹងហើយចឹងហើយពេលដែលបានហូបឆ្អែក គេក៏ចាប់ផ្តើមស្លាប់ដោយសារតែជំងឺធ្លាយក្រពះ។

ក៖ ហើយអ៊ីកាលជំនាក់នឹងអ៊ីមានដែលឈើដែលឬទេពេលដែលចឹង?

ខ៖
និយាយទៅកាលនឹងបើនិយាយទៅនឹងខ្ញុំវាមិនបានឈឺអីទេកាលនឹងនោះវារាងហឺរតែម្ដងនឹង
កាលនឹង

គ៖ វារាងតូចស្ដើងៗវាហឺរពេកអត់អីសំរាប់ស៊ី

ខ៖
អ្នកខ្លះទៅគេថាកដៃឡើងប៉ិនៗដងវែកធំពេលដែលបានអោនចឹងទៅយកដៃនឹងទៅជ្រតក្បា
លជង្គង់ដូចជាមនុស្សចាស់។

គ៖
អូងទៅមើលនឹងសម័យនឹងដូចទៅនឹងកាលដែលគេបញ្ចាំងនៅក្នុងរោងកុននឹងរឿងដែលគេបា
នចាក់បញ្ចាំងនឹងចឹងដែលនឹងវាដូចគ្នាទេវាស្រដៀងគ្នាទេ

ខ៖ កាលនឹងមើលទៅព្រះសង្គ្រួមម៉េចទៅវាចឹងឯង

ក៖ ចាស!

គ៖ កាលនឹងដូចជាអាអីគេ?

ខ៖ ដូចព្រះង្គ្រួមចឹង

គ៖
អាគេចង់ថតនោះដែលគេបានបញ្ចាំងកាលដែលជំនាន់៧មករានឹងវាដូចគ្នាចឹងដូចគ្នាបេះមិន
ចេញ។

ខ៖ នឹងហើយវាបានដូចគ្នាចឹងអូន។

ក៖ ចាស!

គ៖ ដូចគ្នាចឹង។

ក៖ ហើយដោយសារតែនៅក្នុងតំបន់និមួយៗនឹងវាដូចគ្នាចឹងដែលចាស

គ៖ វាដូចគ្នាដែលតែវាភាគតិចណាស់ដែលថានៅក្នុងកន្លែងខ្លះចឹងទៅនឹងវារាងឆ្អែកចឹងទៅ

ខ៖ ចាស!វាភាគតិចណាស់ដែលវាបានហូបឆ្អែកនឹងនោះ ជាពិសេសកាលនឹងនោះវាគេបានបែងចែកដូចជាយើងនឹងវា១៧មេសា ចំណែកអ្នកមូលដ្ឋាននឹងគេហៅថាអ្នក១៨មេសា ហើយគេអ្នក១៨នឹងគេមិនសូវជាលំបាកដូចជាយើងនឹងនោះទេតែហើយអ្នក១៧មេសានឹងគេបានលុតដំ គេអោយយើងនឹងទៅកន្លែងដែលគេសំរាប់លុនដំយើងនឹងតែម្តង។

គ៖ គេហៅកន្លែងនេពន្ធសក្តីភូមិ។

ខ៖ នឹងហើយ ហើយកាលនឹងមិនមែនចេះតែថាទេណាកាលនឹងបើគេអោយយើងនឹងទៅជីកបន្លាយវិញនឹងគេអោយយើងនឹងទៅជីកបន្លាយឡើងវាមិនចេះតែថានោះទេដូចជាខ្ញុំនឹងវិញណាវាអោយទៅជីកបន្លាយនឹងឡើងដាក់អោយជីកទទឹងចំនួន១ម៉ែត្រគីបហើយបណ្តាយវិញចំនន១កន្លះគីបហើយជំរៅឡើង១ម៉ែត្រហើយវាអោយយើងនឹងជាអ្នករែកខ្លួនឯងទៀតនឹងចឹងហើយថាវានិងវាអោយប្រើយើងនឹងកាប់ហើយត្រូវរែកដីនឹងខ្លួនឯងទៀតហើយទៅជញ្ជូនទៅខ្លួនឯងទៀតគិតតែជញ្ជូនតែម្តង១ថ្ងៃៗនឹង។

ក៖ ហឺ!

ខ៖ ដល់តែហើយបានជាគេអោយយើងនឹងបានឈប់សំរាប់តែបើថាដល់មិនហើយនឹងគេមិនបានអោយយើងនឹងទៅសំរាកនោះទេប៉ុន្តែកាលនឹងបើយើងមានគ្នាចំនួន២នាក់ចឹងទៅគេអោយយើងនឹងបានបង្វាសគ្នាសំរាប់ជួយគ្នាចឹងទៅដូចជាម្នាក់គាត់ជាអ្នកកាប់ហើយម្នាក់រែកព្រោះអីកាលនឹងបើយើងធ្វើចំនួន២ម៉ែត្រ៩ជ្រុងចឹងទៅកាលនឹងគេមានម្នាក់គេជាអ្នកដែលកាប់ចឹងទៅហើយមានម្នាក់ទៀតនឹងគេគឺជាអ្នកដែលជួយរែកចឹងទៅកាលនឹងព្រោះអីមើលគ្នាដែលបើមានម្នាក់នឹងគាត់រាងថារាងហត់ហើយនឹងអោយគេជាអ្នករែកទៅហើយម្នាក់ទៀតនឹងគេជាអ្នកកាប់វិញចឹងទៅយើងបានដូចគ្នាបាន។

ក៖ ចាស!

ខ៖ នឹងហើយយើងបានដូចគ្នាធ្វើចឹង។

ក៖ ចាស!ហើយចឹងកាលនឹងគេបានអោយអ៊ីធ្វើកាប់ដីអីនឹងសំរាប់យកកន្លែងធ្វើស្រែ?

ខ៖ នឹងកាប់ដីមិនមែនយកទៅធ្វើស្រែនោះទេតែគេបានកាប់ដីនឹងសំរាប់លើកជាទំនប់

គ៖ នឹងគាប់ដីនឹងគេសំរាប់យកទៅធ្វើជាទំនប់តែម្តងនឹង

ខ៖ ចាស!គេយកទៅធ្វើជាទំនប់នឹងណា

ក៖ ចាស!

គ៖
ដូចជាទំនប់នៅទួលក្រសាំងអីនឹងសុទ្ធតែជាអាពតវាជាអ្នកប្រើគេអោយលើកសុទ្ធតែជាអ្នកលើនឹងកាលនឹង។

ខ៖ កាលនឹងគេលើទំនប់នឹងគេបានលើសំរាប់ធ្វើជាទំនុបលើជាប្រឡាយទឹក

គ៖ គេលើកធ្វើទំនុបនឹង

ខ៖
កាលនឹងជំនាន់នឹងបើសិនជាមិនលើកធ្វើជាប្រឡាយនឹងទំនប់ចឹងនោះទេកាលនឹងគ្មានទឹកសំរាប់នឹងបង្ហូរធ្វើស្រែនោះទេ។

ក៖ ចាស!

ខ៖
ដល់ចឹងហើយបានជាអាពតនឹងវាបាននិយាយថាបើយើងធ្វើស្រែបង្ហាសនឹងមេយយើងបានហូបបាយតែបើថាយើងធ្វើស្រែបង្ហាសនឹងបន្លាយនឹងយើងហូបនឹងបបរពួកនឹងបាននិយាយចឹងកាលនៅជំនាន់នឹងណា

ក៖ ចាស!

ខ៖
ចុះកាលនៅជំនាន់នឹងនោះមេយបើមានភ្លៀងចឹងបានជាយើងនឹងបានជីកបន្លាយទាំងអស់គ្នា

នឹងចឹងហើយបានជាវាអោយយើងនឹងបានយកអីសំរាប់ប្រជាជនយើងនឹងបានទៅជីកបន្លាយ ហើយកាលនឹងគេបានអោយទៅជីកបន្លាយហើយ។
និយាយថាកាលនឹងខ្ញុំបានរស់មកដល់សព្វថ្ងៃនឹងនោះគឺដោយសារតែខ្ញុំនឹងបានចូលក្នុងកងយុវ៉ន ដែលគេហៅកងយុវ៉ននឹងថាគេកងចល័តស្រុកឥឡូវនឹងដូចថា ដូចជាពេលដែលយើងនឹងទៅភ្នំពេញនឹងចឹងដូចថាពីនឹងទៅខេត្តចឹងហាំ អូដូចថាត្រូវទៅកំពង់ស្ពឺទៅកំពង់ចាមអីចឹងទៅណាវាបានឆ្លងខេត្តចឹងបាន បាននៅរស់។

កៈ ចុះកាលជំនាន់សម័យនឹងអ៊ុំឆ្លងទៅខេត្តផ្សេងនឹងដោយដើរទៅ?

ខៈ ចាសកាលនឹងអត់មានអីនោះទេកាលនឹងអ៊ុំបានទៅដោយសារការដើរថ្មើរជើង ពេលយប់នៅកន្លែងណាចឹងត្រូវទៅស្នាក់នៅកន្លែងនឹង កុំមកថាឥឡូវនឹងយើងបានទៅដល់កន្លែងមួយនឹងដែលគេថាជានៅក្នុងភូមិផ្សេងអីចឹង ចឹងហើយដល់ពេលដែលយើងបានទៅថាដូចជានៅក្នុងភូមិ ក ហើយយើងត្រូវទៅភូមិ ខ អីចឹង

គៈ គេអោយយើងត្រូវតែទៅតែម្តង

ខៈ កាលនឹងយើងទៅនឹងមិនមែនទៅម្នាក់ឯងនោះទេកាលនឹងយើងបានទៅគ្នាច្រើននាក់ ឧបមាថាគេមានក្រុមរបស់គេចឹងហើយក្នុង១ក្រុមនឹងមានសមាជិត៤ទៅ១០ឬក៏២០នាក់ចឹងទៅ យើងបានទៅតាមក្រុមមានកងកុមារ កងចល័ត កងយុវ៉ន យើងទៅនឹងយើងទៅជាមួយនឹងកងក្រុមគេចឹងទៅហើយបើថាយប់នៅកន្លែងណាចឹងយើងទៅដេកនៅកន្លែងនឹងចឹងទៅសំរាប់កន្លែងសំរាប់នឹងគេបានសំរាកនៅក្នុងសហាករនឹងហើយចំណែកព្រលឹមឡើងនឹងគេបានចាប់ផើមទៅទៀត។

កៈ ចាសហើយចំពោះកងយុវ៉ននឹងតើមានមូលហេតុអ្វីដែលគេបានអោយយើងនឹងចូលចឹង?

ខៈ
កងយុវ៉នចូលដើម្បីចូលទៅនឹងដោយសារតែនឹងព្រោះអីកាលនឹងវាមិនសូវបានឈរនៅក្នុងកន្លែងធ្វើពេញដូចកងចល័តហើយកងយុវ៉តនឹងគ្រាន់តែស្ទើងស្រូវនឹងបោចស្មៅអីចឹងតូចទេនេះឯងហើយចំណែកឯកងចល័តនឹងវាត្រូវទាំងបោចទាំងស្ទូង បើស្ទូងអីនឹងត្រូវស្ទូងអោយត្រង់ប្រទាត់ទៀតគេសុទ្ធតែវាស់ខ្សែសិនអោយត្រង់បន្ទាប់ទៀតតែបើយយើងធ្វើណាំ

គេដាក់ខ្សែអោយយើងស្ទូងត្រង់បន្ទាប់ទៀតចឹងហើយបើកងយុវ័ននឹងគេអាចនឹងលើកលែងចោលព្រោះអីកាលនឹងវានៅតូចនៅរាងស្ទើរហាំ។

ក៖ ចាស!ចឹងគឺកាលនឹងដោយសារតែអីនៅរាងស្ទើរតូច។

ខ៖ នឹងហើយនៅតូចហើយនៅវារាងស្ទើរចឹងទៅកាលនឹង។

ក៖ ចាស!

ខ៖
នឹងហើយនៅតូចស្ទើរចឹងហើយបានទៅចូលនៅក្នុងកងយុវ័នកាលនឹងបើនៅរាងស្ទើរចឹងគេបានរាងលើកលែងអោយយើងខ្លះព្រោះអីកាលនឹងយើងវារាងនៅស្ទើរចឹងហើយគេបានជួយលើលែងអោយមិនដូចជានៅក្នុងកងចល័តនោះទេវាមិនបានប្រើយើងពេញលក្ខណៈនោះទេ។

គ៖ កាលនឹងគេបានរាប់ចូលដែលតែយើងអាចសូមគេចូល

ខ៖
កាលនឹងយើងបានចេះតែនេះទៅកាលនឹងដូចថាយើងចេះឆ្លៀតចូលនៅក្នុងកងនឹងវាបានហូបមិនសូវជាឆ្អែកដែលនឹងកាលនឹងនោះចឹងហើយពេលនឹងខ្ញុំនឹងឃើញថាអោយកន្លែងណាដែលខ្ញុំរាងបានញុំាបាយបានឆ្អែកនឹងស្រួលខ្ញុំទៅនឹងហើយកាលនឹង

គ៖ ទៅកន្លែងណានឹងកាលនឹងវាមិនចេះតែអោយយើងនឹងបានចូលទៅស្រួលនោះទេ។

ខ៖ នឹងហើយវាមិនសូវទេតែវារាងបានគ្រាន់បើ

គ៖ គេមិនងាយអោយយើងបានទៅណានោះទេ។

ខ៖ គេអោយមេកងគេនឹងបានអោយទៅដែល
គេអោយទៅដូចថាពេលដែលយើងសុំគេទៅចឹងទៅគេអោយយើងទៅតើកាលនឹង។

គ៖ បើគេអោយចឹងបើសិនជាយើងចង់ទៅថៃអីចឹងកាលនឹងទៅបានដែរចឹង?ហាហា

ខ៖
អត់ទេគេមិនអោយយើងទៅទេព្រោះនៅជំនាន់អាពតនឹងកាលនឹងវាពិកបាកណាស់កាលនឹង
នោះបើឃើញតែខុសបន្តិចនឹង

គ៖ គេមិនទៅទុកយើងទេ

ខ៖
ប្រហែលនៅក្នុងខេត្តស្វាយរៀងផងខ្ញុំបានមើលឃើញនៅនឹងភ្នែកកុំពុងតែនៅជ្រូតស្រូវៗចឹង
ហៅហើយហៅគេទៅហើយកាលនឹងហៅគេទៅវៃចោល។

ក៖ អឺយ!

ខ៖
១អាទេះគោអីនឹងគេដឹកយកទៅហើយចឹងបានខ្ញុំនឹកឃើញហើយយកមកពិភាក្សាគ្នាថាហ៊ីនឹង
យើង
យើងមិនដឹងជាថ្ងៃណានោះទេបើទំរាំគេសារក្រោយនឹងគេទំរាំតែច្រូតស្រូវហើយនឹងគេហៅដឹ
ងអាទេះទៅហើយ ហើយចុះចំណែកយើងវិញ
ជាអ្នកនៅនឹងដែលមិនដឹងគេយកទៅថ្ងៃណាថ្ងៃនៃអីចឹងនោះទេចឹងហើយបានថាគេនឹងបាន
ឃើញគេយកទៅវៃចោលដែលតែបានថាវាមិនដឹងថាពេលណាហើយនឹងថ្ងៃណាចឹងហើយនឹង
យើងក៏បានគិតហើយធ្វើបន្ទើរទៅវាមិនដឹងជាដល់វេនខ្លួនឯងពេលណានោះទេ
នឹងឃើញថាគេយកយើងទៅថ្ងៃណាយើងទៅថ្ងៃនឹងតោះគេចវាមិនរួចហាហាហា។

ក៖ ចាស!

គ៖
កាលនឹងបានបន់ស្រន់ព្រះទេវតាថាអោយទេវតាអើយសូមជួយខ្ញុំអីចឹងទៅកាលនឹងអោយផុត
ទុក្ខភ័យចឹងណា។

ខ៖ មានតែប៉ុណ្ណឹងនោះទេកាលនឹង

គ៖ តែថាដល់ដំណាក់កាលនឹងវាភ័យចឹងហើយ

ក៖ ចាស!ហើយកាលនឹងអីបានសំណាងមែនទែនដែលបានរួចគេចផុតរួចពីជំនាន់នឹងមក។

ខ៖
ចាស!កាលនឹងវាមកពីចេកផងពេលនេះនឹងពេលដែលដល់ពេលជិតបែកចឹងគេបានអោយ
យើងនឹងទៅស្ទូងស្រូវទៀតណា អោយពួកខ្ញុំនឹងទៅ
អោយពួកខ្ញុំដែលនៅស្មើរនឹងព្រោះអីកាលនៅជំនាន់នឹងត្រឹមបានអាយុ១៤ទៅ១៥ឆ្នាំនឹងចឹង
ហើយវានៅវាងស្មើរវាមិនទាន់ជានៅធំប៉ុន្មាននោះទេអូនដល់ហើយទៅវាបានប្រើទៅជញ្ជូន
ស្រូវទៅទាំងល្អីៗស្រូវនឹងពីសហាករមួយទៅឆ្លងទៅសហាករមួយ
បើប្រៀបធៀបនឹងយើងវិញនឹងពីឃុំសង្កាត់មួយទៅឃុំសង្កាត់មួយទៀត។

ក៖ ចាស!

ខ៖ វាមិនមែនជិតទេណាកាលនឹងដើរហាហើយទូល
ហើយបើថាយើងទូលតិចអីមិនថាទេវាទូលនឹងយ៉ាងតិចណាស់ក៏១តៅជាងដែល។

ក៖ ហឺ!

ខ៖ អាប៉ោវស្រូវពីដើមយកអោយយើងទូលនឹងណា

ក៖ ចាស!

ខ៖ កាលនឹងបានទូលទៅឆ្លងស្រុកឆ្លងនេះនឹងណា

ក៖ ហឺ!

ខ៖
នឹងហើយគេបានអោយទូលជញ្ជូនទៅហឺបានប្រមូលពីសហាករគេនឹងកាលនៅជំនាន់នឹងដែល
គេជិតបែរហាហ៎ចឹងហើយរត់
រត់ពីសហាករគេនឹងដែលយើងបានជញ្ជូនផលពីសហាករគេយកមកដាក់នៅក្នុងសហាកររបស់
យើង។

ក៖ ចាស!

ខ៖ នឹងហើយ ហើយ

ក៖ ហើយកាលនៅជំនាន់នឹងខ្ញុំបានឃើញគេបានពាក់អាវខ្មៅ

ខ៖ នឹងហើយគេពាក់អាវខ្មៅ

ក៖ ដូចជាមានក្រមានឹងសំរាប់ស្រីៗវិញពួកគាត់បានកាត់សក់ត្រឹមក។

ខ៖ នឹងហើយគេកាត់សក់ខ្លី

គ៖ កាលនឹងគេពាក់អាវពណ៌មិនបាននោះទេគេនាំគ្នាយកទៅច្រលក់អស់ហើយ។

ខ៖ គេពាក់អាវខ្មៅនៅជំនាន់នឹង អាវខ្មៅខោខ្មៅ ហើយគេហាអើយគេបានកាត់សក់ខ្លី។

ក៖ ចាស!

ខ៖ ហើយគេបានបង់កក្រមា
ហើយពួកខ្ញុំនឹងភាគច្រើននឹងខាងអ្នក១៧នឹងអត់សូវមានស្បែកជើងពាក់ទេដើរជើងទទេរតែម្តង។

ក៖ អូ!ចឹងក្តៅខ្លាំងណាស់ចឹង។

ខ៖
អូយ!វាវេទនានឹងដើរនឹងបើបានដើរទៅឆ្ងាយទៅកន្លែងវាលស្មៅវិញនឹងដើរសុទ្ធតែមុតដើរដូចជាដើរនៅកន្លែងមានវាស្មៅនឹងដុះនឹងដើរសុទ្ធតែមុតដើរ។

ក៖ ចាស !ហឺយ!

ខ៖
១ម្តងៗនឹងវាចេះតែចង់នឹងស្រែយំដែលនឹងប៉ុន្តែយើងនឹងវាមិនហ៊ានទេខ្លាចគេយកយើងទៅវៃចោលដែល។

ក៖ ចាស!

ខ៖ ចឹងហើយបើគេទៅទៅតាមគេ

កៈ ហើយ

ខៈ ស្រាចតែមេគេនឹងដាក់បញ្ជាមក។

កៈ ចាស!ហើយបបរជាខោអាវអីនឹងគេបានអោយយើងបានប៉ុន្មានដែរ?

គៈ ៣ខែបាន១កំផ្លេ។

កៈ ចឹងហឺស!

ខៈ
ស្រុកគេនឹងទាល់តែវាពាក់ឡើងរហែកហើយនឹងបានវាអោយតែបើវាល្អមៗនឹងវាមិនទៅអោយគេអោយយើងនឹងទៅដេរពាក់វាវិញ។

គៈ វាអោយយើងនឹងទៅដេរហើយប៉ះវាចឹងទៅ

ខៈ វាអោយដេរហើយប៉ះនឹងហើយ

គៈ និយាយរួមទៅ១ឆ្នាំៗអីនឹងគេអោយបាន៣កំផ្លេអូន។

កៈ ចាស!

ខៈ
ហើយការធ្វើការងារនឹងទាល់តែយើងនឹងបានធ្វើអីហើយចឹងហើយបាយហូបហើយជួនកាលនឹងអាចធ្វើដល់ម៉ោង១១យប់នឹង១២អីន់ក៏មានដែរតែបើសិនជាមិនបានធ្វើការទេពេលយប់នឹងត្រូវប្រជុំចឹងគេបានហៅយើងនឹងទៅប្រជុំទាំងយប់អីនឹងក៏បានទៀត
ធ្វើហើយអីនឹងក៏វាហៅទៅប្រជុំ
ហើយការប្រជុំនឹងវាហៅអោយទៅអង្គុយនៅទាល់តែម៉ោង១១យប់នឹង១២យប់អីនឹងក៏មានដែរហើសកាលនៅជំនាន់នឹងនោះវាមិនថាគេមិនថាយើងនឹងកាលនឹងត្រូវតែប្រជុំទាំងអស់គ្នានឹងកាលនឹង។

កៈ ចាស!

ខ៖
ហើយទៅបើពេលណាហ័កដូចជាបានមមៀលញ៉ឹកខ្លាំងពេកចឹងទៅពេលដែលបានហូបបាយ
ហើយនឹងគេបានហៅអោយទៅធ្វើការនឹងទៅស្ទូងទៀតហើយ
គេអោយទៅប្រជុំអីនឹងទាំងយប់នឹងហើយរាវស្ទូងអីនឹងទាំងយប់នឹងក៏មានដែរ។

ក៖ ចាស!

គ៖ មានអង្គដែលនឹងកាលនឹងតែវាមិនទៅអោយយើងនឹងបានស៊ីទេ។

ខ៖ នឹងហើយវាមិនអោយយើងស៊ីបានគ្រាប់គ្រាន់អីខំធ្វើចង់ងាប់។

ក៖ ហើយកាលនឹងបើវាលំបាកក្នុងការហូបចឹងអ៊ីមានបានធ្លាប់ល្មើសនឹងច្បាប់គេដែរឬទេ?

ខ៖ ចាស!

ក៖ អ៊ីមានធ្លាប់ល្មើសនឹងច្បាប់គេដែលឬទេ?

ខ៖ អត់ហ៊ានទេលួចអីនឹង

គ៖ ហូសៗៗៗ

ខ៖ អត់ហ៊ានលួចរបស់គេនោះទេកាលនឹងខ្លាចងាប់ណាស់។

គ៖ ខ្លាចគេយកទៅសំលាប់ចោល។

ខ៖ កុំតែថាឡើយរបស់គេនឹងតែរបស់យើងនឹងក៏យកមិនហ៊ានទៅយកផង

គ៖ កាលនឹងយើងមានរបស់ខ្លួនឯងនឹងមានដាំដំឡូងខ្លួនឯងនឹង។

ខ៖
របស់ខ្លួនឯងនឹងដូចជាដំឡូងអីនឹងតែវាចេះតែមិនអោយយើងទេបើថាយើងហ៊ានប៉េះរបស់ដែ
លយើងបានដាំនឹងវាថាយើងនឹងសុទ្ធតែលួចយើងបានដាក់ដាំជារបស់ឯងនឹងណាហើយពេល
លបានផលហើយនឹងសុទ្ធតែមិនអោយប៉េះ
ហើយបើថាអ្នកដែលទៅរកត្រីណាពេលដែលបានទៅរកបានហើយនឹងគេមិនអោយនឹងសុទ្ធ

តែដាក់នៅក្នុងកំសៀវបើគេមកនឹងហើយយើងដាំទឹកតែតាមពិតស្ងោរមាន់នឹងអីនឹងនៅក្នុងកំសៀវនឹងនឹង។

គ៖ នៅនឹងងាប់ហើយឯង

ខ៖ បើគេបានឃើញជាក់ស្ដែងគេថាវាមិនមែនជារបស់យើងនោះទេយើងបានលួចអង្គា។

ក៖ ចាស!

ខ៖ នឹងហើយចឹងហើយគេក៏យកយើងនឹងទៅសំលាប់ចោលទៅ។

ក៖ ចាស!

ខ៖
អានឹងគេមិនមែនថាយកយើងនឹងទៅសំលាប់ចោលទេកាលនឹងគេថាយកយើងនឹងទៅរៀនសូត្រ។

ក៖ ចាស!

ខ៖ ហើយពេលដែលគេនាំទៅរៀនសូត្រនឹងបានបាត់ខ្លួនតែម្ដង។

ក៖ ចាស!ចឹងអ៊ីអត់ដែរនឹងបានល្មើសនឹងគេទេណ៎?

ខ៖ ចាស!
អត់ដែលបាននឹងល្មើសនឹងគេទេព្រោះអីកាលនឹងជំនាន់នឹងយើងនឹងសុទ្ធតែនៅជាកំលាំងស្រី១ចឹងហើយទៅយើងមិនដឹងជាទៅល្មើសអីយើងមិនដឹងជាទៅរកឯណាទៅរកអីអត់មាននៅឯណាអត់មានកន្លែងដែលត្រូវលួចបានព្រោះអីកាលនឹងសុទ្ធតែមានកងការពារគេដែលគេបានចល័តកាលនឹងមិនហ៊ានលួចនោះទេកាលនឹង
បើថាមានប៉េះអាដំណាំដំណោចអីនឹងដូចជាដើមឈើដើមព្រៃអីដែលវាបានដុះនឹងអានឹងខ្ញុំបានប៉េះមែន ប៉េះវាយកមកធ្វើហូប។

ក៖ ចាស!

ខ៖ កាលនឹងខ្ញុំបានហូបអស់ហើយមានតាំងពីអើយដើមកំផ្លឹងក៏បានហូប
អើយមើមបន្លើសកបានហូប ហូបអស់ហើយ ក្តួចក៏ហូប

ក៖ ហឺ!

ខ៖ យកមកធ្វើយកមកត្រាំទឹក
យកមកត្រាំទឹកទៅថារបស់នឹងវាមានជាតិពុលចឹងទៅយកទៅត្រាំទឹកទៅក៏បានហាន់វាហើយ
ប្តូរវា៩ទៅ១០ដង ទឹកនឹងមិនមែនទឹកស្អីនោះទេទឹកនៅក្នុងរន្ធដៅអាបេ
នៅរន្ធដៅអាបេកាលនៅជំនាន់នឹងគ្មានទឹកប្រើនោះទេកាលនឹងព្រោះអីកាលនឹងទឹកវានៅអូឆ្ងា
យណាស់ចឹងហើយរន្ធអាបេនៅក្រោយផ្ទះនឹងយើងបានដាក់ប្រើអីផ្តេរផ្តាយនោះទេពេលដែល
បានមេឃភ្លៀងមកយើងទុកទឹកនឹងប្រើទៅ។

ក៖ ចាស!

ខ៖
យើងបានទុកទឹកនឹងសំរាប់ប្រើតែដល់ពេលអើយត្រាំទឹករបស់ដែលថាវាពុលណាត្រាំទឹកទៅ
ត្រូវចាក់ចោលទឹកនឹងទាល់តែវារាងយូរណា
ដល់ពេលដែលរុយទៅទុមលែងងាប់បានយើងយកមកធ្វើហូបបាន។

ក៖ អូចឹងត្រូវប្រើរយៈពេលប្រហែលប៉ុន្មានទៅ?ប្រហែលជាយូរហើយមើលទៅក្នុង១ខែអី?

ខ៖ ប្រើរយៈពេលលប្រហែលជា២ទៅ៣ថ្ងៃ។

ក៖ អូប្រហែលជា២ទៅ៣ថ្ងៃទេហ៎

ខ៖
ពេលដែលយើងនឹងបានត្រាំនៅក្នុងទឹកនឹងហើយយើងត្រូវតែយកទឹកនឹងយកទៅចាក់ចោលវា
មួយសារហើយកាលនៅក្នុងជំនាន់នឹងអីកាលនឹងវាមានផ្លែដង្កោវារាងដូចផ្លែពផ្លឿហា។

ក៖ ចាស!

ខ៖ នឹងហើយយើងអាចយកវាមកហូបបានជំនួយពេលដែលយើងនឹងវាអត់ឃ្លាន។

កៈ ចាស!

ខៈ នឹងហើយ!

កៈ
ហើយកាលនៅសម័យនឹងគេមានធ្លាប់បានគេធ្វើបានដែលឬទេកាលនឹងនៅក្នុងសម័យនឹង?

ខៈ
កាលនឹងនៅជំនាន់នឹងនោះអត់ដែលដូចថាពេលនឹងយើងវារាងនៅតូចៗដែលចឹងចឹងគេមិនបានធ្លាប់ធ្វើបាបយើងផងអត់មានផង។

កៈ ចាស!

ខៈ ចាស!

កៈ ហើយចុះអ៊ីមានបានចង់ចាំអ្វីជាងគេនៅក្នុងសម័យអាពតនឹងរហូតមកដល់សម័យឥឡូវ?

ខៈ
បើចង់ចាំនឹងខ្ញុំបានចង់ចាំជាងគេនឹងចង់ចាំនឹងពេលណាដែលយើងឃ្លានពេលណាដែលបានយើងឃ្លានហើយពេលបានធ្វើការហើយនឹងអត់មានអ្វីសំរាប់អោយហូបចឹងហើយនឹងយើងបានចង់ចាំជាងគេយើងចង់ចាំពេលនឹង
ព្រោះអីពេលនឹងយើងខំប្រឹងធ្វើហើយយើងឃ្លានយើងហឺរតែយើងអត់មានអ្វីសំរាប់ហូបចឹងហើយម្នាក់ៗឃ្លានដល់ស្លាប់។

កៈ ហូយ!

ខៈ នឹងហើយ!

កៈ
ចាសហើយបន្ទាប់ពីបានដាច់អាពតមកនឹងអ៊ីមានមុខរបរអ្វីគេដែរ?ហើយមានជីវិតយ៉ាងណាហើយមានការតស៊ូយ៉ាងណាខ្លះ?

ខ៖

ខ្ញុំហ៎កាលដែលបានបែកអាពតនឹងហើយនៅអើយនៅជាមួយនឹងបងនឹងប្អូននៅឯក្នុងស្រុកហានឹងហើយនៅជាមួយនឹងបងនៅជាមួយនឹងម្ដាយមីងនៅស្រុកអើយពេលដែលខ្ញុំបានជំលៀសទៅនឹងខ្ញុំបានបែកអាពតហើយខ្ញុំបានទៅស្រុកមកនៅជាមួយនឹងគេនៅក្នុងខេត្តពោធិសាត់។

ក៖ចាស!

ខ៖

នឹងហើយទៅនឹងជាមួយនឹងគេនឹងផ្ទាល់តែម្ដងបានធ្វើស្រែធ្វើចំការរកណ្ហយអីសំរាប់ទៅស្ទួងត្រីគេធ្វើនៅឯស្រុកខាងពោធិសាត់ដែលនៅឯស្រុកនឹង
ប៉ុន្តែកាលនឹងខ្ញុំនៅនឹងក្នុងខុសពីកន្លែងអាពតដែលកាលនឹងនៅក្នុងស្រុកអើយនៅឯនេះនៅឯក្នុងស្រុកព្រះអង្គលយើងនេះព្រះមង្គលបឹងខ្លាលយើងនេះឥឡូវនឹងគេហៅស្អីគេទេ
ស្អីនៅបឹងខ្នាលចូលទៅស្រុកព្រះមង្គលនឹងនៅស្រុកបឹងព្រាលនឹងខ្ញុំនៅនឹង
ខ្ញុំបាននៅជាមួយគេនៅឯនឹងខ្ញុំនៅនឹងគាត់ជាអ្នកមានចិត្តធម៌កាលនឹងគាត់បានហៅខ្ញុំនឹងអោយទៅនៅជាមួយខ្ញុំក៏បានទៅនៅជាមួយនឹងគេចឹងទៅហើយខ្ញុំក៏បានទៅជួយធ្វើស្រែធ្វើចំការធ្វើស្រែចឹងទៅព្រោះអីនៅឯស្រុកនឹងកាលនឹងគេធ្វើស្រែនោះទេ
ពេលដែលធ្វើស្រែបានចឹងទៅគេបានលក់ហើយគេអោយលុយយកមកស្រុកវិញ
ឃើញថាខ្ញុំនឹងមិននៅនឹងទេចឹងហើយខ្ញុំយកលុយនឹងយកមកជួបជុំបងនឹងប្អូននៅឯស្រុកកំណើត។
ពេលដែលបានមកដល់នឹងម្ដាយខ្ញុំនឹងអត់មាននោះទេមានតែម្ដាយមីងនឹងយាយរបស់ខ្ញុំនោះទេ។
យាយខាងម្ដាយនឹងលោកយាយខាងឪពុកនឹងនឹងមានជីតាដូតាយាយអីនឹងនៅខាងឪពុកខ្ញុំនឹងគាត់នៅទាំងអស់ ។

ក៖ ចាស

ខ៖

ពេលនឹងមានមានឹងមីងអីទាំងអស់តែមិនមានបងប្អូនបង្កើតនោះទេព្រោះអីកាលនឹងបងនឹងប្អូនបង្កើតនឹងគាត់បានស្លាប់ទៅអស់ហើយ។

ក៖ ចាស!

ខ៖
នឹងហើយដល់ពេលដែលបានមកនៅជាមួយនឹងគាត់ចឹងទៅក៏មានគ្រួសារហើយបានជាមកលក់បាយបានបងប្អូនគេបានហៅមកជួយលក់បាយនៅក្នុងទីក្រុងភ្នំពេញយើងនេះ។

ក៖ ចាស!

ខ៖
កាលនឹងនៅលក់នៅជិតផ្សារអូរឡាំពិកយើងនឹងកាលនឹងខ្ញុំទៅលក់បាយជាមួយនឹងបងប្អូនខ្ញុំនឹងបានមានគ្រួសារទៅចាស។

ក៖ ចាស!អ៊ីបានរៀបការនៅក្នុងឆ្នាំណាដែល?

ខ៖ ខ្ញុំបានរៀបការនឹងនៅក្នុងឆ្នាំ១៩៣៦។

គ៖ កាលនឹងបានរៀបការអីនឹងហូស

ក៖
ចាស!ហើយចឹងកាលនឹងអ៊ីបានរៀបការនឹងដូចថាពេលនឹងអ៊ីហើយនឹងលោកពូកនឹងបានស្រលាញ់គ្នាចិត្តដោយចិត្តឬក៏ឪពុកគាត់ជាអ្នកផ្សំផ្គុំអោយ?

ខ៖ អត់ទេ

ក៖ ចឹងឪពុកម្ដាយអ៊ីគាត់ជាអ្នកដែលបានរៀបចំអោយ?

ខ៖
អត់ទេមីងមាជាអ្នករៀបចំអោយពេលនឹងខ្ញុំបាននឹងឃើញថាគាត់នឹងបានមកចូលស្ដីដណ្ដឹងខ្ញុំនឹងគេបានពេញចិត្តយើង។
ហើយទៅពេលនឹងមីងនឹងគេក៏ថាខាងគេនឹងគេក៏កំព្រីកំព្រាដែលចឹងគេនឹងមានបងនឹងប្អូនចំនួន៣នាក់ហើយដល់ពេលខ្ញុំនឹងមានអើយកាលនឹងខ្ញុំវាអត់មានបងនឹងប្អូនចឹងហើយអាចមើលទៅវាថាអាចនៅជាមួយនឹងគ្នាបានចឹងទៅគាត់ក៏បានផ្សំផ្គុំអោយយើងទៅតាមកាលពិតនឹងយើងមិនដែលបាននឹងជួបមុខហើយស្គាល់គ្នាពីមុននឹងមកសោះ។

កៈ គាត់មានឈ្មោះអ្វីដែលប្តីរបស់អ៊ី?

ខៈ ប្តីរបស់ខ្ញុំនឹងគាត់មានឈ្មោះថា ចន យ៉ាន។

កៈ តើគាត់មានស្រុកកំណើតនៅឯណាដែរ?

ខៈ គាត់មានទីលំនៅក្នុងស្រុកកោះធំដែរនឹង។

កៈ ចាស!គាត់មានទីលំនៅនឹងដូចគ្នា?

ខៈ
ចាស!គ្រាន់តែថាគាត់នឹងនៅរាងឆ្ងាយគាត់នៅពីមន្ទីស្រុកទៀតប្រហែលជា១គីឡូដីអីនោះផ្ទះគាត់នឹងនៅណុងប៉ុន្តែគាត់នឹងបាននៅជាមួយនឹងគេដែលប្តីរបស់ខ្ញុំនឹងគ្រួសាររបស់ខ្ញុំនឹងគាត់បាននៅជាមួយនឹងគេ។ នៅជាមួយនឹងគេជាអ្នកធ្វើកង់កាលនឹងពីដើម
ហើយគាត់ក៏បានធ្វើកង់ដែរចឹងហើយកាលនឹងគាត់ជាអ្នកធ្វើកង់។

កៈ ចាស!ហើយចុះឥឡូវវិញគាត់មានមុខរបរជាអ្វីដែរ?

ខៈ គាត់មានមុខរបរជាអ្នករត់ម៉ូតូឌុបណាអូនកាលនឹងអស់ពីធ្វើជាជាងកង់គាត់បានរត់
ហើយពេលដែលបានមកនៅភ្នំពេញជាលើដំបូងចឹងគាត់បានប៉ះកង់ហើយគាត់បានប៉ះកង់នឹងនៅកន្លែងផ្លូវធំចឹងគេមិនអោយយើងនឹងធ្វើណា។

កៈ ចាស។!

ខៈ ចាស!វាបានប៉ះពាល់ដល់ខ្សែងណៃ

កៈ ផ្លូវសាធារណៈ

ខៈ
ផ្លូវសាធារណៈនឹងហើយចឹងហើយបានជាគាត់ចាប់ផ្តើមរត់ម៉ូតកង់ឌុបហើយពេលដែលរត់អត់បានចឹងក៏ទៅរត់កង់បី
ហើយអត់បានចឹងក៏ទៅរត់ស៊ីខ្លូលចឹងហើយឥឡូវនឹងបានជាប់មករត់ម៉ូតូឌុបមករហាត់មកដល់សព្វថ្ងៃនឹងបានជាប់មករហូតមកហើយនឹងវាចឹង។

កៈ ហើយគាត់មានអាយុប៉ុន្មានហើយ?

ខៈ ប្តីរបស់ខ្ញុំនឹងគាត់មានអាយុ៥៨ឆ្នាំហើយគាត់កើតនៅក្នុងឆ្នាំឆ្លូវ។

កៈ ចាស!ហើយដូចថា
ដូចថាគាត់មកដល់ឥឡូវនឹងដូចថាគាត់មានបានធ្លាប់ប្រាប់អ៊ីថាគាត់ជួបការលំបាកដែរឬទេ?

ខៈ
គាត់បានពិបាកមកនឹងដូចតែគ្នានឹងកាលនឹងតែគ្រាន់តែថាកាលនឹងនៅឯស្រុកទន្លេនឹងវាមិនស្រុកពិបាកដូចជានៅក្នុងស្រុករបស់ខ្ញុំ។

កៈ ចឹងគាត់ធ្លាប់និយាយប្រាប់អ៊ី?

ខៈចាស! ខាងខ្ញុំនឹងគេមិនអោយស្ងូវបានហូបទេតែខាងគាត់គេអោយហូបបានបបូរ

គៈ ខាងគាត់នឹងគេមិនស្ងូវជាបានយកទៅវៃចោលនោះទេ។

ខៈ
នឹងហើយខាងគាត់នឹងគេអោយហូបបានច្រើនហើយគេមិនស្ងូវយកទៅវៃចោលនោះទេតែចំណែកឯខាងខ្ញុំនឹងវិញគេមិនស្ងូវជាបានអោយហូបទេហើយគេបានយកមនុស្សទៅវៃចោលខាងខ្ញុំឯងនេក។

កៈ ចាស!

ខៈ វារាងគួសមកាលនឹងខាងគាត់វាមិនទៅពិបាកនោះទេ។

គៈ ខាងនេះនឹងគេមិនយកទៅវៃចោលនោះទេតែគេបានអត់បាយយកតែម្តង។

ខៈ នឹងហើយខាងពោធិសាត់ អត់បាយស្លាប់

គៈ អត់បាយសំរាប់ស៊ីតែម្តង។

ខៈ បើខាងកោះធំខាងទន្លេយើងនេះអត់អត់បាយទេប៉ុន្តែគ្រាន់តែគេបានយកទៅវៃចោល។

គៈគេយកទៅវៃចោលគេតឹងរឹង។

ខ៖ គេតឹងរឹងខុសគ្នាទៅតាមកន្លែងនឹងចឹងវាខុសគ្នា។

ក៖ ចាស!

ខ៖ ចាស!ខុសគ្នាចឹងណាអូន។

ក៖ ចាស!

ខ៖ ចាស!

ក៖ ហើយសព្វថ្ងៃនឹងអ៊ីមានកូនបានប៉ុន្មាននាក់ហើយ?

ខ៖ ខ្ញុំមានកូនចំនួន៤នាក់ហើយ។

ក៖ ស្រីប៉ុន្មានប្រុសប៉ុន្មានដែរ?

ខ៖ ប្រុសទាំងអស់។

ក៖ ប្រុសទាំងអស់?

ខ៖ ចាស!ប្រុសទាំងអស់។

ក៖ ចាស!ចឹងពួកគាត់មានឈ្មោះអ្វីខ្លះទៅ?

ខ៖ អឺយកូនបងគេមានឈ្មោះថា យ៉ាន ចំរើន កូនទី២មានឈ្មោះថា ចាន់បូរា កូនទី៣មានឈ្មោះថា ប៊ុនយ៉ានបូរេន សុទ្ធតែប្រុសទាំងអស់។

ក៖ ចាស!

ខ៖ ប៉ុន្តែកូនទាំង៣នាក់នឹងវាមានតែវាខ្សត់កូនស្រីហើយគេម្នាក់ៗនឹងគេមានការងារធ្វើអស់ហើយតែនៅកូនតូចនៅកូនទី៤ដែលនៅតូចនឹងគេមានអាយុ១៥ឆ្នាំ អាយុនឹងគេកំពុងពេញនៅរៀន។

ក៖ គេរៀននៅឯណាដែលនៅវិទ្យាល័យ?

ខ៖ អត់ទេគេរៀននៅថ្នាក់ទី៧។

កៈ ចាសអូនៅថ្នាក់អនុវិទ្យាល័យចាស។

ខៈ គេនៅរាងតូចជាងគេអានឹងចឹងអានឹងគេហៅអនុវិទ្យាល័យចឹងហើយ?

កៈ ចាស!នៅថ្នាក់អនុវិទ្យាល័យ។

ខៈ គេរៀននៅថ្នាក់បានត្រឹមថ្នាក់ទី៧នឹង។

កៈ ចាសហើយគាត់ផ្សេងទៀតនឹងគាត់បានរៀបការហើយ?

ខៈ នៅទេមិនទាន់ទេ។

កៈ ប៉ុន្តែនឹងគាត់គ្រាន់តែបានការងារធ្វើហើយ?

ខៈ ចាសគាត់បានមានការងារធ្វើគ្រាប់ៗគ្នាអស់ហើយកូនបងនឹងគេធ្វើជាជាងដេរ ហើយបើកូនទី២នឹងគាត់រៀនមិនទាន់បានចប់នោះទេព្រោះអីកាលនឹងគាត់មិនបានរៀនតែឥឡូវនឹងគាត់បានរៀនចូលឆ្នាំទី៣ហើយនៅមហាវិទ្យាល័យហើយគេបានរៀន នៅក្នុងផ្នែកគ្រប់គ្រងpizza ហើយបើកូនទាំងបីវិញនឹងគេរៀនចប់ខាងផ្នែករៀបចំDecorationចាស។

កៈ ចាសអ៊ី!

ខៈ នឹងហើយគាត់បានការងារខាងផ្នែកDesign នំខេក។

កៈ អូ!ចាស!

ខៈ នឹងហើយនឹងហើយគេបានចូលធ្វើការងារជាអ្នកDesignនំខេកចាស។

កៈ ហើយសព្វថ្ងៃនឹងអ៊ីបាននៅជុំជាមួយនឹងក្រុមគ្រួសារ?

ខៈ
ក្រុមគ្រួសាររបស់ខ្ញុំនឹងគឺបាននៅជុំគ្នាទាំងអស់នឹងអត់តែខ្ញុំព្រោះអីខ្ញុំវាពិកបាកនឹងទៅមកពេក ព្រោះអីពេលដល់ម៉ោង៥ព្រឹកនឹងខ្ញុំបានងើបឡើងដាក់ដាំបាយហើយមិនហ៊ានទៅផ្ទះព្រោះអីខ្លាចមានបញ្ហាខ្លាចពេលដែលជិះជិតភ្លឺនឹងខ្លាចក្លែងលោមានអ្នកណាគេស្រវឹងអីគេជិះប៉ះពាល់ចឹងទៅណា។

កៈ ចាស!

ខ៖ ហើយចឹងកុំអោយពិបាកខកដំណើរចឹងហើយក៏នៅនឹង
នៅដេកនៅនេះចឹងទៅដល់ពេលមានបុណ្យទានអីបានខ្ញុំបានទៅផ្ទះ។

ក៖ ចាស!

ខ៖មានរវល់អីនឹងបានខ្ញុំទៅផ្ទះ។

ក៖ ចាសៗ!

គ៖ នៅផ្ទះបងប្អូនឯងនឹង។

ខ៖ នៅផ្ទះបងប្អូនឯង។

ក៖
ចាសៗ!ហើយអ៊ីកាលនៅពីក្មេងមករហូតមកដល់ឥឡូវនេះមានធ្លាប់ដូចថាមានក្ដីស្រមៃតាំងពីតូចមកនឹងចង់ធ្វើជាអ្វីដែរឬទេ?

ខ៖ អើយក្ដីស្រមៃហោស
កាលពីជំនាន់មុខនឹងគ្មានក្ដីស្រមៃអីនោះទេដូចថាយើងនៅមានកំរិតនៅវាងស្មើរ
នៅស្មើរនឹងយើងរៀនវាមិនទាន់បានចប់ វាគ្មានអីនោះទេអូនកាលជំនាន់នឹងនោះ។

គ៖ កើតមកនឹងវាលំបាករហូតមក។

ខ៖
កើតមកវាលំបាករហូតនឹងរកក្ដីស្រមៃអីគ្រាន់ថាយើងអោយបានក្ដីស្រមៃអីចឹងគ្រាន់ថាយើង

គ៖ វាមិនដូចជាក្មេងឥឡូវនោះទេគ្មានឥឡូវនឹងគេមានក្ដីស្រមៃច្រើនណាស់

ខ៖
កាលនឹងយើងមានជីវៈភាពនឹងវាមិនសូវបានជាធូធានឹងហើយក្មេងៗឥឡូវនឹងគេមានក្ដីស្រមៃច្រើនតែបើថាខ្ញុំនឹងអត់មានទេក្ដីស្រមៃនឹងនោះវាមិននឹកឃើញនោះទេ គ្រានតែថា

គ៖ វាគ្មានក្ដីស្រមៃនោះទេកាលនៅជំនាន់នឹងនោះព្រោះអីស្រមៃវាមិនកើតទេ

ខ៖ គ្រាន់តែថាអោយបានជីវៈភាពល្អប្រសើរប្ដូរប្ដូរទៅបានហើយ។

គ៖
ហើយកាលនឹងវាគ្មានបានក្ដីស្រមៃអីនឹងនោះទេមានតែខ្លាចគេយកទៅវៃចោលតែប៉ុណ្ណឹងនោះទេ។

ខ៖ នឹងហើយកាលនឹងវាមិនដឹងថាត្រូវស្រមៃនឹងទៅធ្វើអីនៅកន្លែងណានោះទេ ហើយបើឥឡូវនឹងវាគ្មានស្រមៃអីទៀតសម័យនឹងបើយើងអាយុវ៉ៃយវាបានប៉ុណ្ណឹងហើយនឹង។

គ៖ អើ បើយើងវាឡើងប៉ុន្មានឆ្នាំហើយនឹងស្រមៃអីទៀត។

ក៖ ចាស!

ខ៖ នឹងហើយ!

គ៖ ហើយកាលនឹងយើងរៀនក៏បានតិច។

ខ៖ នឹងហើយយើងរៀនក៏បានតិចធ្វើអ្វីកើតនោះទេ។

ក៖ ចឹងឥឡូវនឹងអ៊ីក៏អត់មានដែរ?

ខ៖ ចាស!

ក៖ ចឹងអ៊ីមានគំរោងអីសំរាប់ជីវិតរបស់ខ្លួនឯងដែរឬទេ?

ខ៖ ហឺយ
អ៊ីអត់មានគំរោងអីនោះទេអ៊ីអោយតែថានៅបានជុំគ្រួសារទៅបានសុខសប្បាយទៅបានហើយ
។

ក៖ ចាស!

ខ៖ ព្រោះអីកូនៗនឹងអនាគតទៅគេនឹងស្រមៃ មានស្រមៃអីនឹងជារឿងរបស់គាត់នឹងណា។

ក៖ ចាសៗ!

ខ៖យើងចាស់ហើយនឹងមិនដឹងថាត្រូវស្រមៃចង់ធ្វើអ្វីទៀតនោះទេកំលាំងវាចេះតែដុនដាបទៅ ហើយព្រោះធ្វើការងារនឹងវាហត់នឿយ។

កៈ ចាស!

ខៈ ចាស!

កៈ
ហើយអ៊ីដូចថាអ៊ីមានបទពិសោធន៍ជីវិតច្រើនចឹងអ៊ីនបទពិសោធន៍អ្វីគេខ្លះដែលធ្វើអោយអ៊ីបានចង់ចាំរហូតមកដល់ឥឡូវនឹង?

ខៈ អ៊ីអាពតមាន តាំងពីសម័យពីក្មេងមករហូតមកដល់ឥឡូវនឹងហ៎?

កៈ ចាស!

ខៈ
បទពិសោធន៍នឹងមានស្អីទេមានតែធ្វើជាចុងភៅនឹងគ្រាន់តែបទពិសោធន៍ចុងភៅនឹងជាង២០ហើយគ្រាន់តែធ្វើជាចុងភៅនឹងមក។

កៈ អ៊ីធ្វើមុខម្ហូបរបស់ខ្មែរយើង?

ខៈ នឹងហើយមុខម្ហូបរបស់ខ្មែរយើងនឹង។

កៈ ចឹងម្ហូបខ្មែរយើងនឹងអ៊ីចេះបានទាំងអស់តែម្តង?

ខៈ ម្ហូបខ្មែរនឹងអ៊ីមមានស្លមុខម្ហូបប្រហើរ ស្ងោរ ម្ជូរអីនឹងយើងចេះហើយ
តែចំពោះមុខម្ហូបបបរទេសវិញនឹងអត់ស្វរចេះទេអត់ចេះចឹងម៉ង់ចេះតែមុខម្ហូបខ្មែរ។

កៈ ចាស!

ខៈ
ចាស!ហើយអ៊ីមានបទពិសោធន៍ជាងគេនឹងមានតែធ្វើជាចុងភៅនឹងតែម្តងប៉ុន្តែយើងនឹងវានេះតែម្តងពីមុខមកនឹងយើងក៏ធ្លាប់ដែល
ពេលដែលខ្ញុំនឹងបានរៀបំក្រុមគ្រួសារនឹងខ្ញុំក៏ធ្លាប់ដែរប៉ុន្តែយើងវាបានធ្លាប់លក់បបរអើយមានលក់បបរនឹងនំប័ងសាច់អីនឹងអើយ

ដែលពេលនឹងអឺធ្លាប់បានលក់នៅមុខផ្ទះអីគេនឹងក៏អឺធ្លាប់ជួបដែលធ្លាប់លក់បាយដែលចឹងហើយពេលនឹងខ្ញុំបានឆ្លងកាត់អស់ហើយលក់បានក៏បានលក់ លក់បបរនឹងក៏បានលក់ ។

ក៖
ហើយអ្វីដែលធ្វើអោយអឺពិបាកជាគេបំផុតក្នុងជីវិតរបស់អឺដូចថាពេលដែលអឺបាននឹកឃើញហើយនឹងធ្វើអោយអឺពិបាកចិត្តតែម្តងតើអឺមានដែលឬទេ?

ខ៖
ពិបាកជាងគេនឹងមានតែអើយរឿងការងារនឹងវាមានអ្វីទៅស្រួលនោះទេការងារជាចុងភៅនឹងក៏វាពិបាកដែរនឹង មិនមែនការងារស្រួលទៅបានលុយមកស្រួលនោះទេ
អានឹងមានតែការងារដែលវាពិបាកបានវាបានលុយចាស។

ក៖
ចុះសំរាប់បទពិសោធន៍ជីវិតដែលល្អដែលធ្វើអោយអឺនឹកឃើញហើយវាធ្វើអោយអឺបានសប្បាយចិត្តនឹងមានដែរឬទេ?

ខ៖ អឺមានតែអើយ
អត់មានតែអីនោះទេរឿងបទពិសោធន៍នឹងនោះដូចជាពេលមុននឹងខ្ញុំបានធ្លាប់បានប្រឡងនៅខាងអង្គការនឹងខ្ញុំប្រឡងបានជាប់បានលេខ១ដែលគេអោយយើងទៅប្រឡងក្នុងការធ្វើម្ហូបនឹង
។

ក៖ អង្គការនឹងឈ្មោះអ្វីដែរ?

ខ៖ អង្គការហោសា
កាលពីដើមនឹងខ្ញុំកាលនៅជំនាន់នឹងអើយក្នុងឆ្នាំ២០០៨នឹងខ្ញុំបាននៅក្នុងអង្គការណាសានឹងនៅស្តាអូឡាំពិកយើងនេះ។

ក៖ ចាស!

ខ៖ កាលនឹងខ្ញុំបាននៅនឹងប្រហែលជាជិតបាន១០ឆ្នាំហើយ
បទពិសោធន៍ចុងភៅគ្រាន់តែប្រឡង
យើងកាលនឹងបានគាត់ជួយអោយយើងនឹងកាលនឹងព្រោះអីយើងវាមានកូននៅតូចដល់ចឹង

ធ្វើអីវាមិនកើតយើងក៏បានសុំកន្លែងគេនឹងរៀន
រៀនហើយនឹងគេបានអោយរបបយើងនឹងក្នុង១ថ្ងៃនឹង១រៀល(១រៀលមានន័យស្មើនឹង៥០០០រ)ទៀតទៅរៀននៅកន្លែងគេហើយ
គេបានអោយរបបអោយយើងនឹងបានក្នុង១ថ្ងៃនឹងបាន១រៀលទៀតសំរាប់ក្នុងការធ្វើដំណើរ។
នឹងហើយកន្លែងនឹងបានជាយើងអាចនឹងបានចេះធ្វើម្ហូបអីមកហើយយើងអាចនឹងចេះធ្វើម្ហូបហើយហើយនឹងយើង យើងអាចមានជីវៈភាពអាចនឹងរស់មកដល់សព្វថ្ងៃនឹងចឹងដោយសារអីអានឹងដោយសារតែយើងកាលនឹងបានរៀនធ្វើម្ហូបនឹងផងបានស៊ីឈ្នួលគេផង។
យើងធ្វើនឹងបានប្រាក់ខែទៀត
ពេលនឹងយើងធ្វើម្ហូបហើយនឹងអង្គការនឹងបានអោយប្រាក់ខែអោយយើងទៀតចឹង
យើងបានប្រខែអោយយើង ចឹងហើយបានជាយើងចាប់ផ្តើម
យើងចេះធ្វើម្ហូបធ្វើអីនឹងកាលនឹង។
គ្រាន់ថាចំពោះការធ្វើម្ហូបនឹងយើងចេះដែលគ្រាន់តែថាម្ហូបនឹងវាមានរស់ជាតិឆ្ងាញ់ឬក៏មិនឆ្ងាញ់នឹងយើងមិនដឹងនោះទេទាល់តែយើងរៀនទៅបានយើងមានក្បួនមានខ្នាតរបស់វា
នឹងហើយចាប់ផ្តើមរៀននឹងគេមានក្បួនមានខ្នាតគេអោយយើងរៀនហើយព្រោះអីនៅកន្លែងអង្គការនឹងចឹងគេអោយចុងភៅធ្វើនឹងសុទ្ធតែលំដាប់ផ្កាយ៥ហាំ
សុទ្ធតែមកពីហើយសណ្ឋាគារលំដាក់ផ្កាយ៥ណា
ហើយសណ្ឋាគារលំដាប់ផ្កាយ៥នឹងមានដូចជានៅ Roya ហើយនឹងកង់តាណង់តាលយើងនេះ។
មានឈ្មោះស្អីគេនៅផ្សារដើមគរយើងនេះ។

ក៖ ចាស!

ខ៖ ឈ្មោះស្អីដូចជាInterconនឹងហើយ
អង្គការនឹងសុទ្ធតែធ្វើការងារបំរើអោយសណ្ឋាគារនឹងហើយ
នឹងហើយនៅសណ្ឋាគារនៅRoyaនឹងនៅក្នុងសណ្ឋាគារIntercon។

ក៖ ចាស!ឥឡូវនិងគេបានធ្វើការប្តូរឈ្មោះទៀតហើយ។

ខ៖ ចាស!គេបានប្តូរហើយនឹងគេមិនដឹងជាបានដាក់អីនោះទេបានដឹងតែថាអីចឹង។

ក៖ គេប្តូរជាឈ្មោះGreat Palace ។

ខ៖ នឹងហើយសុទ្ធតែខាងអង្គការនឹង
ហើយមួយទៀតនឹងខាងអង្គការនឹងដែលនឹងមានឈ្មោះថាNGO ។

ក៖ ចាស!

ខ៖ ហើយខាងNGOនឹងហើយមួយទៀតនឹងគេខាងBusinessមួយទៀតនឹងគេហៅណាសាស្ទីគេទេ។

ក៖ នឹងហើយ!

ខ៖ នឹងហើយហើយទៅកាលនឹងខ្ញុំវាបានឈប់យូរដែលហើយ។

ក៖
ចាស!ចឹងទាំងអស់នឹងពេលដែលអ៊ីបាននឹកឃើញហើយនឹងធ្វើអោយអ៊ីបានសប្បាយចិត្តតែម្ដង?

ខ៖
ចាស!ពេលដែលបាននឹងឃើញបាននឹងធ្វើអោយខ្ញុំបានសប្បាយចិត្តតែម្ដងព្រោះអីកាលនឹងបានទៅនឹងរៀនចេះហើយបានប្រាក់ខែប្រាក់អីមកដែលចឹងហាហ៎បានធ្វើម្ហូបអីចឹងអោយគេចឹងហើយបើជាធម្មតាវិញ
នៅនឹងជាមួយនឹងអង្គការនឹងយើងបានប្រាក់ខែហើយយើងបានធ្វើទៅបានឈប់សំរាកអីខ្លះដែរអីចឹងទៅចឹងវាធ្វើអោយយើងរាងបានធូរកំលាំងយើងខ្លះដែរ។
ហើយចំណែកឯរាល់ថ្ងៃនឹងវាក៏មិនមែនទៅលំបាកអីខ្លាំងណាស់ណាដែលទេគ្រាន់តែយើងបានដឹងថារឿងធ្វើម្ហូបនឹងវាជាអាជីពរបស់យើងហើយនឹង។

ក៖ ដោយសារតែយើងស្រលាញ់វាចឹងហើយក៏ធ្វើវាទៅ។

ខ៖ ចាស!ដោយសារតែយើងបានស្រលាញ់វាហើយក៏បានចាប់យកអាជីពនឹងទៅនឹងហើយព្រោះអីវាតាំងពីក្មេងមកដល់ទៅពេលនេះនឹងដល់ពេលដែលវាជាអាជីពរបស់យើងនឹងហើយចឹងបានជាពេលនឹងវាជាអាជីពរបស់យើងបានហើយវាជាអាជីពរបស់យើងនឹងហើយយើងធ្វើតែនៅនឹងម្ហូបនឹងតែម្ដងចឹងហើយបានថាទោះបីយើងវាលំបាកឬស្រណុកនឹងក៏យើងនឹងតែប៉ុណ្ណឹងព្រោះអីវាជាអាជីពរបស់យើងហើយនឹង។

កៈ ចាស!

ខៈ ចាស!

កៈ
ចាស!ចឹងអ៊ីមានពាក្យពេជ្យអ្វីដើម្បីនឹងនិយាយជាចុងក្រោយសំរាប់និយាយទៀតដែរឬទេដូចថាអ៊ីចង់និយាយទាក់នឹងបទពិសោធន៍ល្អៗដែលអ៊ីធ្លាប់បានជួបប្រទះកន្លងមកអ៊ីមានតែ១នឹងឬក៏អ៊ីមានអ្វីផ្សេងៗទៀតដែរ?

ខៈ
មានតែបទពិសោធន៍នឹងហើយអើយបទពិសោធន៍នឹងហើយអើយអត់មានបទពិសោធន៍ក្រៅពីនឹងទាំងបទពិសោធន៍ធ្វើម្ហូបអោយគេនឹងមានមួយទៀតនឹងគឺបទពិសោធន៍មើលក្មេងព្រោះអីនៅអង្គការនឹងគេបានអោយខ្ញុំនឹងមើលក្មេងដែលតើ
គេអោយយើងនឹងទៅមើលក្មេងជំទង់ៗហ៎ដែលមានអាយុ១៥ទៅ១៧ឆ្នាំដែលពួកគាត់ជាស្រ្តីដែលមានវិបាកអីនឹង។

កៈ អឺ!

ខៈចាស!បានមើលថៃក្មេង
បានមើលថៃក្មេងនឹងចឹងវាមានអាម្មរណ៍ថាយើងនឹងដូចជាសប្បាយចិត្តដែលព្រោះអីកាលពីមុនមកនឹងយើងមិនដែលមានកូនស្រីចឹងហើយគេអោយយើងនឹងបានទៅមើលក្មេងៗនឹងគេសុទ្ធតែជាស្រីៗទាំងអស់។

កៈ ចាស!

ខៈ គេបានអោយយើងមើលក្មេងនឹងសុទ្ធតែស្រី។

កៈ ចាស!

ខៈ
ក្នុង១ផ្ទះនឹងមានសុទ្ធតែស្រីហើយគេមាន៨ទៅ១០នាក់ចឹងទៅកាលនឹងអើយហើយចំពោះអាយុរបស់កូនក្មេងនឹងវាមានអាយុប្រហែលជាពី១៥ទៅ១៦ឆ្នាំអីឡើងនឹងទៅបើខ្លះទោ១៧ទៅ១

៨ឆ្នាំដែលគេអោយយើងនឹងមើលនឹង
ហើយក្នុង១ផ្ទះនឹងមានគ្នា១០នាក់អីចឹងទៅគ្នា១០អីចឹងទៅហើយយើងបានធ្វើតែល្អៗសំរាប់គាត់ហើយគាត់ក៏ល្អៗសំរាប់យើងចឹងទៅចឹងហើយយើងក៏បានសប្បាយចិត្តយើងមានអារម្មណ៍ថាសប្បាយចិត្តទៅនឹងហើយ។

កៈ
ចាស!អ៊ីអរគុណអ៊ីច្រើនចឹងជាចុងក្រោយអ៊ីមានពាក្យពេជ្រអ្វីសំរាប់ផ្តាំផ្ញើរដល់អ្នកដែលគាត់បានស្តាប់សំលេងរបស់អ៊ីនឹងដែរឬទេ?

ខៈ អើយខ្ញុំមានពាក្យពេជ្រសំរាប់នឹងជូនពរ
អើយខ្ញុំមានពាក្យសំរាប់នឹងជូនពរអោយគាត់នឹងបានដែងមានតែជួននឹងសំណាងល្អហើយគាត់ដែលបានជួបនឹងអោយជួបតែរឿងល្អៗនឹងហើយអោយគាត់នឹងមានអាជីពនឹងបានដែងនឹងល្អៗនឹងបានគាត់នៅជាប់នឹងដក់នៅក្នុងអារម្មណ៍របស់គាត់នឹងហើយ
ហើយខ្ញុំក៏សូមជូនពរដល់អ្នកដែលបានមកសំភាសន៏នឹងផងហាហា។

ខៈ ចាស!អរគុណចាស!

កៈ សូមអោយបានជោគជ័យចាសអត់មានអីទៀតទេអស់ហើយ។

ខៈ ចាសអរគុណច្រើនអ៊ី!

កៈ ចាស!